គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA. P.O. Box 1145,
Tel: (855) 23 884 150 Fax: (855) 23 883 750 E-mail: comfrel@online.com.kh URL: www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN Saray
ជាប្រធានគណៈកម្មាធិការនាយក និងជាប្រធានសមាគម ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
ជាអនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហិរញ្ញិក និងជានាយក CCPCR

លោក **យៀង វណ្ណា**
Mr. YEANG Vanna
ប្រធាន KKKHRA

លោក **ជីវ យូម៉េង**
Mr. CHIV You Meng
ប្រធាន KYA

លោកស្រី **ពឹង យក់ហៀប**
Ms. PEUNG Yok Hiep
នាយិកា LAC

លោក **យង់ គិមអេង**
Mr. YONG Kim Eng
ប្រធាន PDP Center

លោក **ទូច ទុម្ព**
Mr. TOUCH Tum
នាយក VIGILANCE

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

កញ្ញា **សយ សារា វឌ្ឍនី**
Ms. SAY Sara Vathany
នាយិកា CWCC

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith
**ឥស្សរជន**

លោក **សឺន សែត**
Mr. SEN Set
**ឥស្សរជន**

ស.ប្រ.ក.៣/លេខ ០៧/០៨ គ.ប.ស.យ/អ.ក

# របាយការណ៍សង្ខេប
# ស្តីពី
# ការឃ្លាំមើលសភា និង តំណាងរាស្ត្រ នីតិកាលទី ៣ (២០០៣-២០០៨)
# អំណាច និង ឯករាជភាពរបស់អ្នកតំណាងរាស្ត្រស្ថិតនៅក្រោមឥទ្ធិពលគណបក្សនយោបាយ

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨*

គណៈកម្មាធិការ ខុមហ្វ្រែល សង្កេតឃើញថា ចាប់តាំងពីរដ្ឋសភានីតិកាលទី ៣ ចាប់ផ្តើមដំណើរការ រហូតដល់ជិតចប់អាណត្តិរបស់ខ្លួន **អំណាច និងស្វ័យភាពរបស់អ្នកតំណាងរាស្ត្រ គឺមានកំរិតទាបដែលស្ថិតនៅក្រោមឥទ្ធិពលយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល** (ស្ថាប័ននីតិប្រតិបត្តិ) **និងគណបក្សនយោបាយរបស់ខ្លួន**។ ជាក់ស្តែង មានការជម្រុញយ៉ាងបង្ខំក្នុងការអនុម័តច្បាប់ធម្មនុញ្ញបន្ថែម ដែលកំណត់នីតិវិធីនៃការបោះឆ្នោតជាកញ្ចប់ និងសំដែងការគាំទ្រដោយការលើកដៃ ដើម្បីផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល ប្រធាន អនុប្រធាន និងគណៈ-កម្មការជំនាញរដ្ឋសភាក្នុងពេលជាមួយគ្នាតែម្តង។ ជាមួយគ្នានេះ ក្រោមហេតុផលនៃការ**ប្រាសចាកសមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន** ក្នុងនីតិកាលទី៣ នេះ ធ្វើឱ្យ**អ្នកតំណាងរាស្ត្រចំនួន ១៣ រូប** (ក្នុងចំណោមតំណាងរាស្ត្រចំនួន ៥៦ រូប ដែលបានផ្លាស់ប្តូរ) បានបាត់បង់សមាជិកភាពសភាដោយសារតែមិនពេញចិត្តនឹងគោលនយោបាយ និងគោលជំហររបស់អ្នកដឹកនាំគណបក្ស ហើយបានចាកចេញពីគណបក្សនយោបាយរបស់ខ្លួន ដែលក្នុងនោះមាន **៧ រូប មកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និង ៦ រូប មកពីគណបក្ស សម រង្ស៊ី**។

អ្នកតំណាងរាស្ត្រមិនត្រឹមតែមិនបានធ្វើវិសោធនកម្មមាត្រា ១២០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រង់ចំនុចដែល**ចងសមាជិកភាពជាអ្នកតំណាងរាស្ត្រទៅនឹងសមាជិកភាពរបស់គណបក្សនយោបាយ** តែអ្នកតំណាងរាស្ត្របែរជាបានអនុម័តសេចក្តីស្នើច្បាប់ស្តីពី**លក្ខន្តិកៈតំណាងរាស្ត្រ** ដែលត្រង់មាត្រា ៥ បានចែងថា (*តំណាងរាស្ត្រ មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ*) ដែលមាត្រានេះ គឺជាការ**បន្ថយអភ័យឯកសិទ្ធិរបស់ខ្លួនថែមទៀតផង**។ **ភាពមិនឯករាជ និងសម្ពាធនយោបាយពីគណបក្សនយោបាយបានធ្វើឱ្យសមាជិកសភាត្រូវដើរតាមខ្សែបន្ទាត់ និងគិតពីផលប្រយោជន៏របស់គណបក្សខ្លួនធំជាងប្រជាពលរដ្ឋជាម្ចាស់ឆ្នោត**។

ក្នុងនីតិកាលទី ៣ នេះដែរ រដ្ឋសភាបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាច្រើនមាត្រា ដោយរួមទាំងអនុម័តច្បាប់ធម្មនុញ្ញបន្ថែមផងដែរ ក្រោមហេតុផលដើម្បីធានានូវដំណើរការប្រក្រតីរបស់ស្ថាប័នជាតិ បើទោះបីជាការធ្វើវិសោធនកម្មនោះ ត្រូវបានធ្វើពហិការដោយតំណាងរាស្ត្រមួយចំនួន និងត្រូវបានរិះគន់យ៉ាងខ្លាំងក្លា ដោយក្រុមអង្គការសង្គមស៊ីវិល និងអ្នកវិភាគឯករាជយ៉ាងណាក៏ដោយ។

ស្មារតីរដ្ឋធម្មនុញ្ញដែលត្រូវបានធ្វើវិសោធនកម្ម ក៏រួមមានការបន្ថយសម្លេងភាគច្រើនពីពីរភាគបី មកត្រឹមសម្លេងភាគច្រើនដាច់ខាត (៥០% + ១) សម្រាប់ការបោះឆ្នោតជ្រើសតាំង ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ការអនុម័ត ញត្តិស្តីបន្ទោស ការអនុម័តយល់ព្រម ការទម្លាក់រាជរដ្ឋាភិបាល... ហើយក្រោយការធ្វើវិសោធនកម្មនេះ សម្ព័ន្ធភាពរបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចមានការរង្គោះរង្គើ ដោយគណបក្សប្រជាជនកម្ពុជាបានចាប់ផ្តើមដកតំណែងសំខាន់ៗរបស់រដ្ឋមន្ត្រី អភិបាលខេត្ត អភិបាលខេត្តរង និងមុខងារធំៗក្នុងជួររាជរដ្ឋាភិបាលរបស់មន្ត្រីមកពីគណបក្សហ៊្វុនស៊ិនប៉ិចជាច្រើន ដោយគ្មានការពិភាក្សាជាមួយគណបក្សហ៊្វុនស៊ិនប៉ិចទេ។ អនាគត គោលការណ៍នៃការបែងចែកអំណាចរវាងអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ នឹងត្រូវបានរំលោភយ៉ាងធ្ងន់ធ្ងរ ប្រសិនបើប្រធាន អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មការជំនាញរដ្ឋសភាសុទ្ធតែជាមនុស្សមកពីគណបក្សដឹកនាំរាជរដ្ឋាភិបាល ដូចដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់ព្រមានថា បើគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត នោះដំណែងប្រធានគណៈកម្មការជំនាញ រដ្ឋសភាគឺជាតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា[១]។

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួនកូរ៉ុមសម្រាប់សម័យប្រជុំសភាជាបន្តបន្ទាប់ពីប្រាំពីរភាគដប់ មកត្រឹមប្រាំមួយភាគដប់ និងក្រោយមកមកត្រឹមលើសពាក់កណ្តាល នៃសមាជិកសភាទាំងមូលសម្រាប់ការប្រជុំពេញអង្គរដ្ឋសភា ក្រោមហេតុផលដើម្បីធានានូវដំណើរការស្ថាប័នមួយនេះ បានធ្វើឱ្យចំនួនសមាជិកសភាចូលរួមប្រជុំមានចំនួនតិច ដែលនេះ អាចបញ្ជាក់ថា ចំនួនអ្នកតំណាងរាស្ត្រមិនបានចូលរួមឱ្យបានទូលំទូលាយនៅក្នុងសម័យប្រជុំពេញអង្គរដ្ឋសភានោះទេ។ ជាក់ស្តែង មុននឹងមានការធ្វើវិសោធនកម្មចំនួនកូរ៉ុមមកត្រឹមលើសពីពាក់កណ្តាល (យ៉ាងតិច ៦២ រូប) សមាជិកសភាចូលរួមប្រជុំជាមធ្យមគឺមាន ៩៧ រូប ប៉ុន្តែបន្ទាប់ពីវិសោធនកម្មមក ជាមធ្យមគឺមានតែ ៨៩ រូបប៉ុណ្ណោះ។ ក្នុងនោះ ជាមធ្យមសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាបានចូលរួមច្រើនជាងគេគឺ ៥៨ រូប (ស្មើនឹង ៧៩% នៃចំនួនសមាជិកសភាមកពីគណបក្សនេះសរុប) បន្ទាប់មកសមាជិកសភាគណបក្សសមរង្ស៊ីគឺ ១៤ រូប (ស្មើនឹង ៥៨% នៃចំនួនសមាជិកសភាមកពីគណបក្សនេះសរុប) និងគណបក្សហ៊្វុនស៊ិនប៉ិច គឺ ១៥ រូប (ស្មើនឹង ៥៨% នៃចំនួនសមាជិកសភាមកពីគណបក្សនេះសរុប)។

វិមានរដ្ឋសភាបានធ្វើការផ្លាស់ប្តូរទៅកាន់ទីតាំងថ្មី ដែលចំណាយទឹកប្រាក់សាងសង់អស់ប្រមាណ ២៤ លានដុល្លារ និងធ្វើការសម្ពោធដែលមានការចូលរួមពីបណ្តាស្ថាប័នសភាមកពីប្រទេសជិតខាងដែលចំណាយអស់ប្រមាណ ៥០ម៉ឺនដុល្លារអាមេរិក។ អ្នកតំណាងរាស្ត្រមួយចំនួនយល់ថា ការចំណាយសម្រាប់ការសម្ពោធគឺច្រើនហួសហេតុ ខណៈដែលអ្នកខ្លះថា

---

[១] ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន នៅក្នុងពិធីប្រគល់សញ្ញាប័ត្រដល់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨។

វាជាសំណង់ប្រវត្តិសាស្ត្រសម្រាប់សតវត្សទី ២១ និងជានិមិត្តរូបនៃលទ្ធិប្រជាធិបតេយ្យ ។ ទោះបីអគារថ្មី មានទំហំធំជាងមុនយ៉ាងក៏ដោយ ប៉ុន្តែអ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន **នៅតែមិនត្រូវបានអនុញ្ញាតឱ្យចូលសង្កេតនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការជំនាញទាំង ៩ របស់រដ្ឋសភានោះទេ** ដែលហេតុផលពីមុនថា មកពីបន្ទប់ប្រជុំតូចចង្អៀត ឯហេតុផលបន្ទាប់មកថាជា **កិច្ចប្រជុំសម្ងាត់ផ្ទៃក្នុងវិញ** ។ នៅប្រទេសប្រជាធិបតេយ្យ ការប្រជុំគណៈកម្មការជំនាញរបស់រដ្ឋសភាមិនមែនជា ការប្រជុំសម្ងាត់ផ្ទៃក្នុងទេ មិនត្រឹមប៉ុណ្ណោះ គេបានអញ្ជើញឱ្យប្រជាពលរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន អ្នកជំនាញ-ការ និងអ្នកវិភាគឯករាជ ចូលរួមសង្កេត និងផ្ដល់របាយការណ៍ មតិយោបល់ក្នុងករណីចាំបាច់ ។

ថ្វីត្បិតស្ថាប័នសភាគឺជាស្ថាប័នតំណាងប្រជាពលរដ្ឋក៏ដោយ **ក៏ស្ថាប័នមួយនេះនៅតែបន្តការលំបាកដល់ម្ចាស់ឆ្នោតក៏ដូចជាស្ថាប័នធ្វើការពាក់ព័ន្ធនានាក្នុងការស្នើសុំឯកសារផងដែរ** ។ **វាក៏មានការបង្កើតនូវនីតិវិធីលំបាកផងដែរសម្រាប់ម្ចាស់ឆ្នោតជាប្រជាពលរដ្ឋក្រីក្រ ក៏ដូចជាស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងការផ្ដល់ឯកសារ បណ្ដឹង ឬអនុសាទនានា** ដល់អ្នកតំណាងរាស្ត្របន្ទាប់ពីការផ្លាស់ប្ដូរទៅវិមានថ្មី ។ កាលនៅវិមានរដ្ឋសភាចាស់ រាល់ឯកសារជាពិសេសអនុសាសន៍ទាក់ទងទៅលើសេចក្ដីព្រាងច្បាប់ អាចផ្ញើដល់សមាជិកសភាតាមរយៈប្រអប់សំបុត្រ ដោយមិនចាំបាច់ដាក់ក្នុងស្រោមសំបុត្រ និងដាក់ឈ្មោះតំណាងរាស្ត្រម្នាក់ៗនោះទេ ក៏ប៉ុន្តែនៅពេលនេះរដ្ឋបាលរដ្ឋសភាតម្រូវឱ្យរាល់ការផ្ញើឯកសារទាំងអស់ទោះបីឯកសារដូចគ្នាក៏ដោយ គឺត្រូវដាក់ក្នុងស្រោមសំបុត្រ និងដាក់ឈ្មោះតំណាងរាស្ត្រនីមួយៗ ។

នៅខណៈដែលសភាជិតចប់នីតិកាលទី ៣ របស់ខ្លួន **អគ្គលេខាធិការដ្ឋានរដ្ឋសភាបានចេញគោលការណ៍ណែនាំ**សម្រាប់សាលប្រជុំសភា **ដោយតម្រូវឱ្យអ្នកសង្កេតការណ៍ ក៏ដូចជាម្ចាស់ឆ្នោតមិនត្រូវយកឧបករណ៍ថតសម្លេង ម៉ាស៊ីនថតរូប ទូរស័ព្ទ...** ចូលក្នុងសាលប្រជុំ ។ ប្រការនេះបានបង្កការលំបាកដល់អ្នកសង្កេតការណ៍ក្នុងការកត់ត្រាវិភាគរាល់ខ្លឹម-សាររបស់អ្នកតំណាងរាស្ត្រ ក៏ដូចជាចង់បានរូបភាពសម័យប្រជុំសភាដើម្បីផ្សព្វផ្សាយដល់ម្ចាស់ឆ្នោតផងដែរ ។ មានការលើកឡើងថា រាល់ការថតសម្លេងត្រូវទៅបន្ទប់អ្នកសារព័ត៌មាននៅក្នុងអាគារប្រជុំ ដែលមានថតការប្រជុំសភាផ្សាយតាមទូរទស្សន៍ផ្ទាល់ ក៏ប៉ុន្តែការទៅបន្ទប់អ្នកសារព័ត៌មាននេះមិនអាចធ្វើឱ្យអ្នកសង្កេតការណ៍អង្កេតពីសកម្មភាពនៅសម័យប្រជុំបានពេញលេញឡើយ ។ ពេលខ្លះបន្ទប់អ្នកសារព័ត៌មានមិនត្រូវបានបើកទ្វារទាន់ពេលនោះទេ បើទោះបីជាសភាបានបើកសម័យប្រជុំ និងកំពុងតែប្រជុំក៏ដោយ ។

**រដ្ឋសភាបានចាប់ផ្ដើមដំណើរការសម័យប្រជុំពេញអង្គលើកដំបូងរបស់ខ្លួនកាលពីខែ កក្កដា ឆ្នាំ ២០០៤** ដែលដំណើរការនេះ **មានការយឺតយ៉ាវចំនួន ១១ ខែ** ដោយគិតចាប់តាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៣ កាលពីខែ កក្កដា ឆ្នាំ ២០០៣ ដោយសារវិបត្តិជាប់គាំងនយោបាយ និងបានបញ្ចប់សម័យប្រជុំពេញអង្គ របស់ខ្លួនក្នុងនីតិកាលទី ៣ នេះ នៅថ្ងៃអង្គារ ទី ៨ ខែ មេសា ឆ្នាំ២០០៨ តែបានបើកសម័យប្រជុំពេញអង្គវិសាមញ្ញនៅថ្ងៃទី ៨ ឧសភា ឆ្នាំ ២០០៨ ។ ក្នុងរយៈពេលជាង ៤ ឆ្នាំចុងក្រោយនេះ តាមទិន្នន័យរបស់ខុមហ្វ្រែល **រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់ខ្លួន សរុបចំនួន ១៦៣ កិច្ចប្រជុំ** ដោយបានពិភាក្សា និងអនុម័តលើរបៀបវារៈសរុបចំនួន **១៩៦** ដែលក្នុងនោះ **សេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ចំនួន ៥៩** ច្បាប់ស្ដីពីវិសោធនកម្ម ចំនួន **១៨** កិច្ចព្រមព្រៀងអន្តរជាតិនានាចំនួន **៦៨** និង **៥១** របៀបវារៈផ្សេងៗ ដូចជាការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តសមាជិក រាជរដ្ឋាភិបាល

ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការជំនាញ...។ ជាសរុបមក រដ្ឋសភាក្នុងនីតិកាលទី ៣ នេះ បានអនុម័តសេចក្តីព្រាង/ស្នើច្បាប់/កិច្ចព្រមព្រៀងអន្តរជាតិនានាចំនួន ១៤៥ កើនឡើងប្រមាណ ៧៥% បើប្រៀបធៀបជាមួយសេចក្តីព្រាង/ស្នើច្បាប់/កិច្ចព្រមព្រៀងដែលរដ្ឋសភាបានអនុម័តក្នុងកំឡុងនីតិកាលទី ២ ដែលមានចំនួនសរុប ៨៣[២] ។ ប៉ុន្តែល្បឿននេះបានក្លាយជាការព្រួយបារម្ភទៅវិញថា ជាមធ្យមក្នុងមួយពេលប្រជុំ (មួយព្រឹក) មានអត្ថបទច្បាប់ ឬឯកសារផ្សេងៗ យ៉ាងហោចណាស់ចំនួនមួយត្រូវបានអនុម័ត ឬសម្រេច។ តំណាងរាស្ត្រមួយចំនួន ជាពិសេសអ្នកតំណាងរាស្ត្រគណបក្សជំទាស់ និងគណបក្សហ្វ៊ុនស៊ិនប៉ិចបានលើកឡើងថា ការជជែកពិភាក្សាលើអត្ថបទទាំងនោះមិនសូវបានស៊ីជម្រៅដោយពេលវេលាពិភាក្សាក្នុងសម័យប្រជុំពេញអង្គមានការកម្រិតជាងមុន ឬមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាឱ្យបានលម្អិត។

ការសង្កេតលើសម័យប្រជុំពេញអង្គរកឃើញថា ទោះបីជាមានសេចក្តីព្រាង/ស្នើច្បាបនិងរបៀបវារៈផ្សេងៗទៀតជាច្រើនត្រូវបានអនុម័តក៏ដោយ ការសង្កេតឃើញថា សេចក្តីព្រាង/ស្នើច្បាប់ត្រូវបានអនុម័តដោយគ្មានការកែប្រែខ្លឹមសារតាមការស្នើសុំរបស់តំណាងរាស្ត្រនោះទេ ក្រៅពីការកែប្រែអក្ខរាវិរុទ្ធបន្តិចបន្តួច ឬក៏កែប្រែតាមការស្នើសុំរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ។

សេចក្តីស្នើច្បាប់ដែលស្នើឡើងដោយ តំណាងរាស្ត្រមកពីគណបក្ស សមរង្ស៊ី មិនត្រូវបានសម្រេចយកមកពិភាក្សាក្នុងសម័យប្រជុំសភាពេញអង្គនោះទេ ខណៈដែលសេចក្តីស្នើច្បាប់ដោយតំណាងរាស្ត្រគណបក្សកាន់អំណាច ត្រូវបានសភាពិភាក្សា និងអនុម័ត។ ឧទាហរណ៍ដូចជាសេចក្តីស្នើច្បាប់ស្តីពីឯកពន្ធភាព ដែលស្នើដោយតំណាងរាស្ត្រគណបក្សកាន់អំណាច ត្រូវបានរដ្ឋសភាយកមកពិភាក្សា និងអនុម័ត ខណៈដែលសេចក្តីស្នើច្បាប់ស្តីពីការតម្លើងប្រាក់ខែរបស់មន្ត្រីរាជការ និងនិយោជិតឯកជន ដែលស្នើឡើងដោយតំណាងរាស្ត្រគណបក្ស សមរង្ស៊ី មិនត្រូវបានយកមកពិភាក្សានោះទេ ទោះបីជាច្បាប់នេះមានសារៈសំខាន់ជាងច្បាប់ស្តីពីឯកពន្ធភាពមិនអាចប្រៀបធៀបគ្នាបានយ៉ាងណាក៏ដោយ ។

នៅក្នុងពេញមួយនីតិកាលនេះ រដ្ឋសភាមិនមានឥទ្ធិពលអ្វីទៅលើប្រមុខ និងតំណាងរាជរដ្ឋាភិបាលខ្លាំងក្លានោះទេ បើទោះបីជាសិទ្ធិអំណាចរបស់ខ្លួនក្នុងការកោះហៅ នាយករដ្ឋមន្ត្រី និងតំណាងរាជរដ្ឋាភិបាលមកបំភ្លឺចំពោះមុខរដ្ឋសភាមានចែងក្នុងរដ្ឋធម្មនុញ្ញក៏ដោយ។ ទោះបីអ្នកតំណាងរាស្ត្រត្រូវបំពេញតួនាទីជាអ្នកឃ្លាំមើលការងារនិងជម្រុញការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល តំណាងរាស្ត្រគណបក្សជំទាស់សមរង្ស៊ីបានកោះហៅ និងធ្វើលិខិតទៅនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលជាច្រើន ប៉ុន្តែការឆ្លើយឆ្លងមានចំនួនតិចតួចបំផុត។ មានលិខិតរបស់តំណាងរាស្ត្រគណបក្សជំទាស់យ៉ាងតិចចំនួន ២៣ លិខិត បានដាក់ជូនរាជរដ្ឋាភិបាលដើម្បីស្នើសុំមកបំភ្លឺជុំវិញបញ្ហានានាទាក់ទងនឹងការងាររបស់រាជរដ្ឋាភិបាលនៅសម័យប្រជុំពេញអង្គរដ្ឋសភា ក៏ប៉ុន្តែតំណាងរាជរដ្ឋាភិបាលចូលមកបំភ្លឺតែ ៤ លើកប៉ុណ្ណោះ។ ច្បាប់សំខាន់ៗដែលរាជរដ្ឋាភិបាលយល់ថា ចាំបាច់សម្រាប់កសាងនីតិរដ្ឋ និងដែលបានចែងក្នុងកម្មវិធីនយោបាយរបស់ខ្លួនត្រូវបានអនុម័តតិចតួចបំផុត ហើយមានសមាជិករដ្ឋសភាតិចតួចប៉ុណ្ណោះ ជាពិសេសគឺមកពីគណបក្សសមរង្ស៊ី ដែលជម្រុញឱ្យ

[២] យោងរបាយការណ៍ស្តីពីដំណើរការប្រជុំរដ្ឋសភា នីតិកាលទី ២ (១៩៩៨-២០០៣) របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បោះពុម្ពផ្សាយក្នុងឆ្នាំ ២០០៣។

រាជរដ្ឋាភិបាលបញ្ជូនសេចក្តីព្រាងច្បាប់ទាំងនោះមករដ្ឋសភា។

ច្បាប់សំខាន់ៗដែលមិនទាន់អនុម័តទាំងនោះមានៈ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសារការី-សាធារណៈ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាសាលា ច្បាប់ស្តីពីសមាជជាតិ និងច្បាប់ស្តីការធ្វើវិសោធន-កម្មលើច្បាប់ស្តីពីគណបក្សនយោបាយ។ គួរកត់សំគាល់ថា រដ្ឋសភាខ្លួនឯងផ្ទាល់ក៏មិនបានធ្វើសេចក្តីស្នើច្បាប់ទាំងនេះផងដែរ។

ចំណែកការបញ្ចេញមតិនៅក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាវិញ ខុមហ្វ្រែល សង្កេតឃើញថា **តំណាងរាស្ត្រគណ-បក្សហ្វ៊ុនស៊ិនប៉ិច និងសមរង្ស៊ី ភាគច្រើនបានឡើងបញ្ចេញមតិ និងមានរយៈពេលច្រើនជាងគណបក្សប្រជាជនកម្ពុជា**។

កំឡុងពេលសម័យប្រជុំពេញអង្គរបស់រដ្ឋសភានីតិកាលទី ៣ នេះ មានអ្នកតំណាងរាស្ត្រមកពីគណបក្សទាំង ៣ យ៉ាងតិចចំនួនតែ **៦៩ រូប**[៣] បានឡើងបញ្ចេញមតិយោបល់ពាក់ព័ន្ធនឹងការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នានា និងបញ្ហាផ្សេងៗដូចជា ការងាររាជរដ្ឋាភិបាល កង្វល់របស់ប្រជាពលរដ្ឋជាដើម ដែលមានចំនួនសរុប **៨.៤៩៩ នាទី** ក្នុងនោះរយៈពេលនៃការបញ្ចេញមតិបែបវិជ្ជមានមានតែ **១.៩៤៦ នាទី**ប៉ុណ្ណោះ ខណៈពេលដែលការបញ្ចេញមតិបែបអព្យាក្រឹត **៣.៧៧៤ នាទី** និងបែបអវិជ្ជមាន **២.៧៧៩ នាទី** ។ **តំណាងរាស្ត្រគណបក្សកាន់អំណាចប្រជាជនកម្ពុជា**ដែលបានឡើងបញ្ចេញមតិក៏បានយកពេលវេលាពិភាក្សាក្នុងសម័យប្រជុំ **សរសើរ និងផ្សព្វផ្សាយពីការងាររបស់រាជរដ្ឋាភិបាល និងគណបក្សរបស់ខ្លួនផងដែរ**។ អ្នកតំណាងរាស្ត្រមកពីគណបក្ស**ប្រជាជនកម្ពុជា** មានចំនួន **៣៣ រូប** (ស្មើនឹង **៤៥%** នៃអ្នក-តំណាងរាស្ត្រគណបក្សនេះទាំងអស់ ដែលមានចំនួន ៧៣ រូប) បានឡើងបញ្ចេញមតិយ៉ាងតិចចំនួន **៤៨៧ លើក** ដែលមានរយៈពេលសរុប **២.៤៩៤ នាទី** (ជាមធ្យមនៃតំណាងរាស្ត្រដែលបានបញ្ចេញមតិ អ្នកតំណាងរាស្ត្រមួយរូបបាន បញ្ចេញមតិរយៈពេល ៧៤ នាទី) ក្នុងនោះការបញ្ចេញមតិលើចំនុច**វិជ្ជមាន** មាន **១.០៣៨ នាទី** ដែលភាគច្រើនផ្តោតទៅលើសេចក្តីព្រាងច្បាប់ និងការងាររបស់រាជរដ្ឋាភិបាល (រយៈពេល ៥៨២ នាទី) **អព្យាក្រឹត ១.១៦០ នាទី** និង**អវិជ្ជមាន មានតែ ២៥៦ នាទី**ប៉ុណ្ណោះ ដែលភាគច្រើនគឺរិះគន់គណបក្ស និងតំណាងរាស្ត្រដទៃទៀតដែលមកពីគណបក្សផ្សេងពីខ្លួន ដែលមានរយៈពេល **៩៥ នាទី**។ ចំណែកអ្នកតំណាងរាស្ត្រគណបក្សជំទាស់ **សមរង្ស៊ី** ក៏បានយកពេលវេលានេះ**និយាយបង្អាប់ និងរិះគន់ដល់ការងាររបស់រាជរដ្ឋាភិបាល និងផ្សព្វផ្សាយពីគណបក្សរបស់ខ្លួនផងដែរ**។ មានអ្នកតំណាងរាស្ត្រ គណបក្ស **សមរង្ស៊ី** ចំនួន **១៧ រូប** (ស្មើនឹង **៧១%** នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ ដែលមានចំនួន ២៤ រូប) បានឡើងបញ្ចេញមតិយោបល់យ៉ាងតិចចំនួន **៥១៤ លើក** និងមានរយៈពេលសរុបប្រមាណ **៣.២៧១ នាទី** (ជាមធ្យម តំណាង-រាស្ត្រមួយរូបបញ្ចេញមតិបានរយៈពេល ១៩២ នាទី) ដែលក្នុងនោះការបញ្ចេញមតិលើចំនុចវិជ្ជមាន មាន **២៥៥ នាទី** អព្យាក្រឹត **១.២០៨ នាទី** និង **អវិជ្ជមាន ១.៨០៨ នាទី** ដែលភាគច្រើនគឺ រិះគន់ទៅលើសេចក្តីព្រាងច្បាប់ និងការងាររបស់រាជរដ្ឋាភិបាលដែលមានរយៈពេលដល់ទៅ ១.២៧១ នាទី។ ខណៈដែលតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចខ្លះបាន

---

[៣] យោងតាមទិន្នន័យរបស់ខុមហ្វ្រែល

យកពេលវេលាសរសើរ និងរិះគន់ការងាររបស់រាជរដ្ឋាភិបាលមួយចំនួនក៏ដោយ។ អ្នកតំណាងរាស្ត្រគណបក្ស **ហ៊្វុនស៊ិនប៉ិច** យ៉ាងតិចចំនួន **១៩ រូប** (ស្មើនឹង **៧៣%** នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ ដែលមានចំនួន ២៦ រូប) បានឡើងបញ្ចេញមតិយោបល់យ៉ាងតិចចំនួន **៦២២ លើក** និងមានរយៈពេលសរុបប្រមាណ **២.៧៧៤ នាទី** (ឬជាមធ្យម អ្នកតំណាងរាស្ត្រមួយរូបបញ្ចេញមតិបាន ១៤៦ នាទី) ក្នុងនោះរយៈពេលបញ្ចេញមតិលើចំនុច**វិជ្ជមាន**មាន **៧១៥ នាទី** អព្យាក្រឹត **១.៤០៦ នាទី** និងអវិជ្ជមាន **៦៥៣ នាទី**។

ខុមហ្វ្រែល សង្កេតឃើញថា **ក្រោមការប្រើប្រាស់ហេតុផលចាកប្រធានបទ** ជាពិសេសបន្ទាប់ពីការផ្លាស់ប្តូរប្រធានរដ្ឋសភាពីគណបក្សហ៊្វុនស៊ិនប៉ិចមកគណបក្សប្រជាជនកម្ពុជាវិញ **ប្រធានរដ្ឋសភា/ប្រធានអង្គប្រជុំ ភាគច្រើនបានធ្វើការព្រមានអ្នកតំណាងរាស្ត្រគណបក្សជំទាស់មិនឱ្យនិយាយបន្ត** ឬ បិទឧគ្គោសនស័ព្ទតែម្តង។ ក៏ប៉ុន្តែការលើកឡើងរបស់តំណាងរាស្ត្រគណបក្សកាន់អំណាច ដែលបានឡើងការពាររាជរដ្ឋាភិបាល ឬផ្សព្វផ្សាយ ក៏ដូចជានិយាយពីសមិទ្ធផលនានារបស់រាជរដ្ឋាភិបាលនោះ មិនត្រូវបានប្រធានអង្គប្រជុំចាត់ទុកថាជាការចាកប្រធានបទនោះទេ ហើយក៏មិនមានការបិទឧបករណ៍ឧគ្គោសនស័ព្ទដែរ។

ក្នុងរយៈពេលពេញនីតិកាលទី ៣ នេះ ខុមហ្វ្រែល បានសង្កេត និងទទួលព័ត៌មានថា[៤] មាន**អ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន ១១៧ រូប បានចុះមូលដ្ឋានយ៉ាងតិចចំនួន ៩.៣៨៨ លើក**។ ក្នុងនោះ អ្នកតំណាងរាស្ត្រមកពី គណបក្ស**ប្រជាជនកម្ពុជាចំនួន ៧១រូប** បានចុះមូលដ្ឋានក្នុង និងក្រៅមណ្ឌលរបស់ខ្លួនយ៉ាងតិចចំនួន **៤.៩០២លើក** ឬជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះម្នាក់បានចុះមូលដ្ឋាន **៦៩ លើក** ។ **តំណាងរាស្ត្រគណបក្សសមរង្ស៊ីទាំង ២៤ រូប បានចុះមូលដ្ឋានសរុបចំនួន ៣.៦២៣ លើក** ឬជាមធ្យមតំណាងរាស្ត្រគណបក្សនេះម្នាក់បានចុះ **១៥១ លើក** ហើយអ្នកតំណាងរាស្ត្រគណបក្ស**ហ៊្វុនស៊ិនប៉ិចយ៉ាងតិច ២២ រូប** បានចុះមូលដ្ឋានសរុបចំនួន **៨៦៣ លើក** ឬជាមធ្យមតំណាងរាស្ត្រ គណបក្សនេះ**ម្នាក់បានចុះ ៣៩ លើក**។

ការសង្កេតក៏ឃើញដែរថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រភាគច្រើនលើសលប់ គឺផ្តោតទៅលើមណ្ឌលរបស់ខ្លួន។ **ការចុះទៅមូលដ្ឋានក្នុងមណ្ឌលរបស់ខ្លួនមានរហូតដល់ទៅ ៨.២៥០ លើក** ខណៈដែលការចុះទៅមូលដ្ឋានក្រៅ**មណ្ឌលរបស់ខ្លួនមានចំនួនតែ ១.១៣៨ លើកប៉ុណ្ណោះ**។

គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានដូចជា **ការសាកសួរសុខទុក្ខប្រជាពលរដ្ឋ ចូលរួមវេទិកា អមដំណើរថ្នាក់ដឹកនាំ ពង្រឹងបណ្តាញគណបក្ស និងចុះជួយដោះស្រាយអន្តរាគមន៍**។ ដោយឡែក ការចុះជួយអន្តរាគមន៍ដល់ប្រជាពលរដ្ឋភាគច្រើនធ្វើឡើងដោយតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ក៏ប៉ុន្តែលទ្ធផលហាក់ដូចជាមិនសូវ ទទួលបានភាពវិជ្ជមានទេ ខណៈដែលការអន្តរាគមន៍ដោយអ្នកតំណាងរាស្ត្រមកពី គណបក្សប្រជាជនកម្ពុជា ដែលមានតំណែងក្នុងរាជរដ្ឋាភិបាល គឺទទួលបានលទ្ធផលវិជ្ជមានច្រើន។ ព័ត៌មានដែលខុមហ្វ្រែលទទួលបាន ក្នុងនីតិកាលទី៣នេះ **មានករណី**

---

[៤] ទិន្នន័យរបស់ខុមហ្វ្រែលគិតត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៨

អន្តរាគមន៍ដោយអ្នកតំណាងរាស្ត្រចំនួន ៤២៤ ករណី ដែលក្នុងនោះ **ការជួយអន្តរាគមន៍បានជោគជ័យសរុបមានត្រឹម ១០ ករណី ឬស្មើនឹង ២,៣៦% ប៉ុណ្ណោះ**។

**ការិយាល័យតំណាងរាស្ត្រមួយចំនួនដំណើរការមិនទៀងទាត់ មិនមានសម្ភារៈការិយាល័យ និងថវិកាគ្រប់គ្រាន់ដើម្បីធ្វើសកម្មភាព និងតួនាទីរបស់ខ្លួននោះទេ**។ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលទាំង ២៤ ខេត្ត/ក្រុង មានភារកិច្ចសំខាន់ដើម្បីសម្រួលដល់ការងាររបស់អ្នកតំណាងរាស្ត្រ និងសម្រួលដល់ការប្តឹងតវ៉ា ការលើកឡើងពីតម្រូវការ និងបញ្ហានានារបស់ប្រជាពលរដ្ឋ។ ការិយាល័យទាំងនេះគឺ **មានតែឈ្មោះប៉ុណ្ណោះ និងមិនអាចបំពេញភារកិច្ចរបស់ខ្លួនឱ្យបានសមរម្យឡើយ**[៥]។ អ្នកតំណាងរាស្ត្រខ្លះលើកឡើងថា បុគ្គលិកការិយាល័យតំណាងរាស្ត្រភាគច្រើនមិនអាចរកព័ត៌មានជូនអ្នកតំណាងរាស្ត្របានទេនៅពេលមានពាក្យបណ្តឹងពីប្រជាពលរដ្ឋ ខណៈដែលបុគ្គលិកការិយាល័យតំណាងរាស្ត្រតាមមណ្ឌលនិយាយថា មិនមានថវិកាគ្រប់គ្រាន់ក្នុងការចុះស្រាវជ្រាវរកព័ត៌មានឱ្យបានពិស្តារជូនអ្នកតំណាងរាស្ត្រ។

ការផ្លាស់ប្តូរតំណាងរាស្ត្របានធ្វើឱ្យចំនួន**តំណាងរាស្ត្រជាស្ត្រីមានការកើនឡើងដល់ចំនួន ២៥ រូប** (ស្មើនឹង ២០% នៃអ្នកតំណាងរាស្ត្រសរុប) ដែលលើសពីមុនមានប្រមាណតែ ១០%ប៉ុណ្ណោះ។ ក្នុងកំឡុងពេលផ្លាស់ប្តូរតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា បានធ្វើការផ្លាស់ប្តូរតំណាងរាស្ត្របុរស ដោយអ្នកតំណាងរាស្ត្រស្ត្រីច្រើនជាងគេ ដែលមានចំនួន ៨ រូប គណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន ២ រូប និងគណបក្សសមរង្ស៊ីចំនួន ៣ រូប។

*អនុសាសន៍*

យោងតាមការសង្កេតឃើញខាងលើនេះ ខុមហ្វ្រែល សូមផ្តល់ជាអនុសាសន៍សំខាន់ៗមួយចំនួន ជូនដល់ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិដូចខាងក្រោមនេះ

- *នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលត្រូវគោរពតាមរដ្ឋធម្មនុញ្ញក្នុងការឆ្លើយតប និងចូលមកឆ្លើយផ្ទាល់យ៉ាងសកម្មជាមួយតំណាងរាស្ត្រ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។*
- *បន្តគោរពគោលការណ៍នៃការចែកអំណាចក្នុងរចនាសម្ព័ន្ធដឹកនាំរបស់រដ្ឋសភា ក្នុងចំណោមគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា។*
- *សមាជិករដ្ឋសភាត្រូវមានការផ្តួចផ្តើម និងឆន្ទៈនយោបាយក្នុងការធ្វើវិសោធនកម្មមាត្រា ១២០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីធានាទូវឯករាជភាព និងអំណាចរបស់សមាជិកសភាបុគ្គលម្នាក់ៗ ដោយមិនចងសមាជិកភាពអ្នកតំណាងរាស្ត្រទៅនឹងសមាជិកភាពរបស់គណបក្សនយោបាយ។*
- *បើកចំហឱ្យអ្នកសង្កេតការណ៍ ប្រជាពលរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន និងភាគីពាក់ព័ន្ធ មានលទ្ធភាពចូលស្តាប់ និង/ឬអង្កេតកិច្ចប្រជុំគណៈកម្មការ ជំនាញនីមួយៗរបស់រដ្ឋសភា ជាមួយតំណាងរាជរដ្ឋាភិបាល។*

---

[៥] ប្រសាសន៍របស់ឯកឧត្តម ឡេង ប៉េងឡុង ថ្លែងក្នុង វេទិកាប្រធាន ស្តីពី បទពិសោធន៍នៃការអនុវត្តរបស់គម្រោងគាំទ្រនីតិបញ្ញត្តិកម្ពុជា-កាណាដា ក្នុងខែ ធ្នូ ឆ្នាំ ២០០៧។

- *អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវមានយន្តការច្បាស់លាស់មួយ ក្នុងការសម្រួលដល់ការបញ្ជូនឯកសារនានារបស់ប្រជាពលរដ្ឋទៅអ្នកតំណាងរាស្ត្រ ។*
- *ផ្តល់សេចក្តីព្រាង/ស្នើច្បាប់នានា ដល់ប្រជាពលរដ្ឋ ក៏ដូចជាអ្នកសង្កេតការណ៍ដែលចង់បានឯកសារទាំងនោះយកមកសិក្សា ។*
- *ត្រូវបង្កើនសមត្ថភាព និងថវិកាសម្រាប់ការិយាល័យតំណាងរាស្ត្រដើម្បីឱ្យបុគ្គលិកអាចបំពេញតួនាទីរបស់ខ្លួនជាស្ពានរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ និងជួសជុលកែលម្អអាគារការិយាល័យតំណាងរាស្ត្រចាស់ៗឡើងវិញ ។*
- *គណៈកម្មការជំនាញរដ្ឋសភាត្រូវអញ្ជើញអង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន ផ្នែកឯកជន ឬភាគីពាក់ព័ន្ធចូលរួមផ្តល់យោបល់ លើសេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់ និងការអនុម័តទាំងឡាយដែលប៉ះពាល់ដល់ប្រយោជន៍ពួកគេ ។*
- *រដ្ឋសភាត្រូវពង្រឹងការអនុវត្តគោលការណ៍នៃការបែងចែកអំណាចដូចមានចែងក្នុងមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញជាពិសេសក្នុងការបោះឆ្នោតទុកចិត្តរាជរដ្ឋាភិបាលនៅដើមនីតិកាល ។*
- *អគ្គលេខាធិការ និងមន្ត្រីរដ្ឋបាលនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាទាំងអស់ត្រូវមានជំហរអព្យាក្រឹត ។*

*សម្រាប់ព័ត៌មានលំអិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៥ ០៩១

*បេសកកម្មទី ១ របស់ ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយ ដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ។*

*បេសកកម្មទី ២ របស់ **ខុមហ្វ្រែល** គឺ "ជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះ សាធារណជន យល់យ៉ាងច្បាស់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ មិនត្រឹមតែមុនពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង ។ ដើម្បីសំរេចបេសកកម្មនេះ **ខុមហ្វ្រែល** រៀបចំការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចនានា ។ លើកទឹកចិត្តការចូលរួមការតស៊ូមតិ បញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោត ដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ។ និងចុងក្រោយ ដោយផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បី អាចឱ្យមានការវាយតម្លៃមួយដែលមិនលម្អៀង និងមិនប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោត ។*